ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៦២៨ ឧរថ.អភរ.ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

# ប្រកាស
## ស្តីពីការធ្វើប្រតិភូកម្មអំណាចលើការទារចុះបញ្ជី និងចេញអាជ្ញាប័ណ្ណសិប្បកម្ម និងអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែជូនដល់បណ្តាក្រុង

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-ប្រកាសលេខ ៣៨០ ឧរថ.អធរ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការចុះបញ្ជី និងលក្ខខណ្ឌនៃការផ្តល់ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ

-ប្រកាសអន្តរក្រសួងលេខ ១៧២ឧរថ.អករ.ប្រក លេខ២៩១សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកំណត់ចុះបញ្ជី ពាក្យសុំ(កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ ឈ្នួលដីប្រចាំឆ្នាំនៃតំបន់សម្បទានធ្វើការស្វែងរករ៉ែ និង/ឬធ្វើអាជីវកម្មធនធានរ៉ែ និងសួយសារធនធានរ៉ែ

-យោងលិខិតលេខ ១៧៨/០៤ សជណ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៤ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

## សម្រេច

**ប្រការ ១.**

ផ្ទេរប្រតិភូកម្មអំណាចពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលលើការងារចុះបញ្ជី និងចេញអាជ្ញាប័ណ្ណសិប្បកម្ម និងអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ជូនដល់បណ្ដាក្រុងនៃបណ្ដាខេត្តមួយចំនួនដូចខាងក្រោម៖

- ក្រុងបានលុង ខេត្តរតនគីរី
- ក្រុងបាវិត ខេត្តស្វាយរៀង
- ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
- ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
- ក្រុងដូនកែវ ខេត្តតាកែវ
- ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
- ក្រុងកំពត ខេត្តកំពត
- ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

ដើម្បីសាកល្បងក្នុងការបង្កើតជាមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងក្របខ័ណ្ឌសុំធ្វើអាជីវកម្មធនធានរ៉ែសំណង់ និងកែច្នៃធនធានរ៉ែមានជាអាទិ៍ៈ ខ្សាច់ ក្រួស ដីឥដ្ឋ អាចម៍ដី កែច្នៃថ្មកែវ និងថ្មភក់ក្នុងទ្រង់ទ្រាយជាលក្ខណៈគ្រួសារ នៅតាមតំបន់ និងទីតាំងទាំងឡាយណាដែលស្ថិតនៅក្នុងភូមិសាស្ត្រនៃក្រុងខាងលើ ។

**ប្រការ ២.**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងចេញនូវសេចក្ដីណែនាំអំពីការអនុវត្តន៍លើគំរូបែបបទពាក់ព័ន្ធដល់ការដាក់ពាក្យសុំចុះបញ្ជី និងដាក់ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្ម និងអាជ្ញាប័ណ្ណ កែច្នៃធនធានរ៉ែជូនដល់មន្ត្រីជំនាញនៅការិយាល័យឧស្សាហកម្ម រ៉ែ និងថាមពលប្រចាំក្រុងដែលជាសេនាធិការឲ្យអភិបាលក្រុងខាងលើ ។

**ប្រការ ៣.**

អភិបាលក្រុងបានលុង អភិបាលក្រុងបាវិត អភិបាលក្រុងពោធិ៍សាត់ អភិបាលក្រុងកំពង់ឆ្នាំង អភិបាលក្រុងដូនកែវ អភិបាលក្រុងខេមរភូមិន្ទ អភិបាលក្រុងកំពត និងអភិបាលក្រុងច្បារមន ត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ ជូនមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តនីមួយៗរបស់ខ្លួន ។

**ប្រការ ៤.**

អភិបាលក្រុងបានលុង អភិបាលក្រុងបារិត អភិបាលក្រុងពោធិ៍សាត់ អភិបាលក្រុងកំពង់ឆ្នាំង អភិបាលក្រុងដូនកែវ អភិបាលក្រុងខេមរភូមិន្ទ អភិបាលក្រុងកំពត និងអភិបាលក្រុងច្បាមនត្រូវអនុវត្តតាមប្រកាសនេះ។

**ប្រការ ៥.**

ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

ស៊ុយ_សែម

**<u>កន្លែងទទួល</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលាខេត្តរតនគិរី ស្វាយរៀង ពោធិ៍សាត់ កំពង់ឆ្នាំង តាកែវ កោះកុង កំពត និងកំពង់ស្ពឺ"ដើម្បីជ្រាប"
-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តរតនគិរី ស្វាយរៀង ពោធិ៍សាត់ កំពង់ឆ្នាំង តាកែវ កោះកុង កំពត និងកំពង់ស្ពឺ "ដើម្បីជ្រាប"
-ដូចប្រការ ៤"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ